**UNITED NATIONS**
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

**NATIONS UNIES**
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

Special Representative of the Secretary-General
for Human Rights in Cambodia

តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

COHCHR

## ការដកអភ័យឯកសិទ្ធិសមាជិកសភា
## នៃគណៈបក្សសមរង្ស៊ី និង ការចាប់ខ្លួនលោក ជាម ច័ន្ទនី

តាមទស្សនៈដែលមានឯកសារយោងយ៉ាងត្រឹមត្រូវ ស្តីអំពី កង្វះឯករាជ្យភាពនៃប្រព័ន្ធតុលាការកម្ពុជា លោកតំណាងពិសេស មានការព្រួយបារម្ភយ៉ាងខ្លាំង អំពីការដកអភ័យឯកសិទ្ធិសភា ដែលធ្វើឡើងកាលពីថ្ងៃ ព្រហស្បតិ៍ ទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៥ ទៅលើតំណាងរាស្ត្រចំនួន ៣ រូប មកពីគណបក្សសមរង្ស៊ី គឺ លោក សម រង្ស៊ី លោកជា ប៉ូច និង លោកជាម ច័ន្ទនី ។ លោកតំណាងពិសេស ក៏មានការព្រួយបារម្ភយ៉ាងខ្លាំងដែរ អំពីការចាប់ខ្លួនលោកជាម ច័ន្ទនី នៅថ្ងៃតែមួយនោះ ។ រដ្ឋសភា បានធ្វើការបោះឆ្នោតដកអភ័យឯកសិទ្ធិនេះ នៅក្នុងសម័យប្រជុំជាសម្ងាត់មួយ ដែលអនុម័តតាមរយៈការលើកដៃ ។ សមាជិកសភាចំនួន ៩៨ នាក់ នៃ ១០៣ បានបោះឆ្នោតដកអភ័យឯកសិទ្ធិរបស់លោក ជា ប៉ូច ។ រីឯ សមាជិកសភាចំនួន ៩៧ នាក់ នៃ ១០៤ បានបោះឆ្នោតដកអភ័យឯកសិទ្ធិលោកជាម ច័ន្ទនី និង លោក សម រង្ស៊ី ។ លោក សម រង្ស៊ី និង លោក ជា ប៉ូច ក៏បានចាកចេញពីប្រទេសភ្លាមៗ ។

ការដកអភ័យឯកសិទ្ធិ និង ការចាប់ខ្លួនបានធ្វើឡើង នៅពេលដែលមានវិធានការមួយចំនួនក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ ដែលធ្វើអោយមានការសង្ស័យជាច្រើនទៅលើឆន្ទៈរបស់គណៈបក្សទាំងពីរ ដែលស្ថិតនៅក្នុងរដ្ឋាភិបាលចំរុះ គឺ គណៈបក្សប្រជាជនកម្ពុជា និង គណៈបក្សហ៊្វុនស៊ិនប៉ិច នៅក្នុងដំណើរការប្រជាធិបតេយ្យពហុបក្ស អោយបានល្អត្រឹមត្រូវនោះ ។ ភាពមន្ទិលសង្ស័យទាំងនេះរាប់បញ្ចូលទាំងការបដិសេធន៍មិនផ្តល់អោយគណបក្សសមរង្ស៊ីនូវអសនៈណាមួយនៅក្នុងគណៈកម្មការនានានៃរដ្ឋសភា កិច្ចព្រមព្រៀងមួយរវាងគណបក្សដែលកំពុងកាន់អំណាចទាំងពីរ ក្នុងការពន្យាពេលការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភាអោយបានស្របតាមរដ្ឋធម្មនុញ្ញ និងការខាកខានមិនបានធានាអោយមានជ្រើសរើសមេភូមិដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានជាប់ឆ្នោត ដូចមានចែងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងក្រុមប្រឹក្សាឃុំ សង្កាត់ ។

ការដកអភ័យឯកសិទ្ធិរបស់លោក សម រង្ស៊ី និង លោក ជា ប៉ូច ដោយសារមានបណ្តឹងបរិហារកេរ្តិ៍ រីឯការចាប់ខ្លួន លោក ជាម ច័ន្ទនី ដោយសារគាត់ពាក់ព័ន្ធទៅនឹងការចោទប្រកាន់ដែលធ្វើឡើយដោយលោក នាយករដ្ឋមន្ត្រី កាលពីថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៤ បីថ្ងៃក្រោយពីការបង្កើតរដ្ឋាបាលថ្មីកាលពីថ្ងៃទី ១៥ ខែ កក្កដា ដែលថាគណបក្សសមរង្ស៊ីបានកំពុងតែរៀបចំកំលាំងយោធាដោយសម្ងាត់ ។ ឥស្សរជនមួយចំនួនដែលស្ថិតនៅក្រៅស្ថាប័នចារកម្មយោធា និងតុលាការយោធាហាក់បីដូចជាមានការជឿជាក់ទៅលើការចោទប្រកាន់ដោយគ្មានភស្តុតាងនេះ ហើយមានមន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជាមួយចំនួនធ្លាប់បានប្រកាសជាសាធារណៈថា អាជ្ញាធរមិនបានរកឃើញនូវភស្តុតាងណាមួយនៃកងកំលាំងប្រដាប់អាវុធត្រូវបានកំពុងបង្កើតនេះឡើយ ។

លោក ជាម ច័ន្ទនី បានត្រូវចាប់ខ្លួននៅប្រហែលម៉ោង ៧ ល្ងាច កាលពីថ្ងៃទី ០៣ ខែ កុម្ភៈ ក្រោយពីការដកអភ័យឯកសិទ្ធិរបស់លោក ហើយដីកាសំរាប់ចាប់ខ្លួនលោក ត្រូវបានចេញដោយព្រះរាជអាជ្ញាអមតុលាការយោធា ។ បទចោទប្រកាន់នោះរួមមាន "ការរៀបចំកំលាំងប្រដាប់អាវុធខុសច្បាប់" និង "អំពើឆបោក" តាមមាត្រា ៣៦ និង មាត្រា ៤៥ នៃបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ និងច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌ សំរាប់អនុវត្តនៅ ប្រទេសកម្ពុជាក្នុងសម័យអន្តរកាល (ច្បាប់អ៊ុនតាក់) ។ លោក ជាម ច័ន្ទនីត្រូវបាននាំខ្លួនទៅកាន់ការិយាល័យអយ្យការយោធាដើម្បីធ្វើការសួរចំឡើយ ហើយបន្ទាប់មកត្រូវបាននាំខ្លួនទៅឃុំនៅពន្ធនាគារយោធានៅទីក្រុងភ្នំពេញ ដែលស្ថិតនៅក្បែរការិយាល័យអយ្យការយោធា។ កិច្ចខិតខំប្រឹងប្រែងទាំងឡាយដែលធ្វើឡើងដោយការិយាល័យ នៃឧត្តមស្នងការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាដើម្បីជួបសួរសុខទុក្ខគាត់នៅតែព្យាយាមបន្ត។

លោកតំណាងពិសេស សូមអំពាវនាវអោយមានការដោះលែងលោក ជាម ច័ន្ទនី ជាបន្ទាន់ និង ដោយគ្មានលក្ខខណ្ឌ ។ លោក ជាម ច័ន្ទនី គឺជាជនស៊ីវិលម្នាក់ ហេតុដូច្នេះគាត់មិនត្រូវស្ថិតនៅក្រោមយុត្តាធិការនៃតុលាការយោធាឡើយ ។

អភ័យឯកសិទ្ធិ គឺសំរាប់ការពារសមាជិកសភាអោយរួចផុតពីការប្តឹងផ្តល់ រឺក៏ការចោទប្រកាន់នានា ដោយគ្មានមូលដ្ឋានច្បាស់លាស់ ដែលអាចជាហេតុផលនៃរឿងនយោបាយ រឺត្រូវបានធ្វើឡើងដោយមានចេតនាអាក្រក់ ។ ការប្រព្រឹត្តត្រឹមត្រូវចំពោះអភ័យឯកសិទ្ធិសភា គឺសំខាន់ណាស់ក្នុងការធានាអោយមានឯករាជ្យភាពនៃរដ្ឋសភា ។ មាត្រា ៨០ នៃ រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ របស់ប្រទេសកម្ពុជាចែងថា "ការចោទប្រកាន់ ការចាប់ខ្លួន រឺការឃុំខ្លួនទៅលើសមាជិករដ្ឋសភា ត្រូវធ្វើឡើងដោយមានការអនុញ្ញាតពីរដ្ឋសភា រឺដោយគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ក្នុងចន្លោះសម័យប្រជុំតែប៉ុណ្ណោះ លើកលែងតែក្នុងករណីបទល្មើសជាក់ស្តែង" ។ ក្នុងករណីនេះ អាជ្ញាធរមានសមត្ថកិច្ចត្រូវរាយការណ៍ភ្លាមទៅកាន់រដ្ឋសភា រឺទៅកាន់គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា ដើម្បីធ្វើការសម្រេច ។ មាត្រានេះចែងផងដែរថា "សេចក្តីសម្រេចដែលធ្វើឡើងដោយគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវតែដាក់ជូនទៅរដ្ឋសភាដើម្បីពិនិត្យក្នុងសម័យប្រជុំបន្ទាប់ ដើម្បីធ្វើការបោះឆ្នោតសម្រេចដោយសំលេង ២ ភាគ ៣ នៃសមាជិកសភាទាំងអស់" ។

ការវិវត្តន៍ទាំងនេះ បានបង្កអោយមានការព្រួយបារម្ភយ៉ាងច្រើន អំពីទម្រង់បែបអត្តាធិបតេយ្យមួយរបស់រដ្ឋាភិបាល ដែលកំពុងតែកើនឡើង និងការព្រួយបារម្ភពីអនាគតនៃរបបប្រជាធិបតេយ្យនៅប្រទេសកម្ពុជា ។ លោកតំណាងពិសេស សូមអំពាវនាវដល់រដ្ឋសភាជាតិផ្តល់អភ័យឯកសិទ្ធិជូនដល់សមាជិកសភាទាំងបីរូបឡើងវិញជាបន្ទាន់ ហើយផ្សព្វផ្សាយជាសាធារណៈអំពីរបាយការណ៍សម័យប្រជុំសម្ងាត់របស់ខ្លួន និងធានាថា សមាជិកសភានៃគណៈបក្សប្រឆាំងត្រូវបានផ្តល់ជូនអសនៈនៅក្នុងគណៈកម្មការណាមួយរបស់រដ្ឋសភា ។

ថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០០៥

#10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587 E-mail: cohchr@online.com.kh
ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា លេខ ១០ ផ្លូវលេខ ៣០២ សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន ភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: ៨៥៥-២៣ ៩៨៧ ៦៧១ / ៩៨៧ ៦៧២ / ៩៩៣ ៥៩០ / ៩៩៣ ៥៩១ / ឬ ២១៦ ៣៤២ ទូរសារ: ៨៥៥-២៣ ២១២ ៥៧៩ ឬ ២១៣ ៥៨៧